# វិធីដាំគូលែន

## ១.ការរៀបចំរណ្តៅ:

- ត្រូវជីករណ្តៅ៦តឹកបួនជ្រុង និង ជំរៅ៦តឹក




- រោយកំបោរសប្រមាណ២ស្លាបព្រាបាយក្នុងរណ្តៅ
- ត្រូវដាក់ផេះឬអង្កាម,កំប្លោក,ចំបើងពុក,អាចម៍មាន់ឬអាចម៍ជ្រូកឬអាចម៍គោមួយស្រទាប់កំរាស់១តឹករួចដាក់ដីពីលើ១តឹកធ្វើយ៉ាងនេះរហូតទាល់តែពេញរណ្តៅ ។




- ត្រូវទុករណ្តៅរៀបចំហើយក្នុងរយៈពេល២ ទៅ ៣ អាទិត្យ ។
- ចំងាយពីរណ្តៅមួយទៅរណ្តៅមួយមានប្រវែង ៨ ម៉ែត្រ ។

## ២.ការដាំ:

- កូនគូលែនត្រូវរក្សាផ្ទាំទុក១អាទិត្យមុនដាំ
- ផ្អាកស្រោចទឹក២ថ្ងៃមុនដាំដើម្បីកុំអោយបែកដីនិងឫស ។
- មុនដាំត្រូវជញ្ជូនកូនគូលែនដាក់ក្បែររណ្តៅទាំងអស់ ។
- ត្រូវបកថង់ចេញធ្វើយ៉ាងណាកុំអោយបែកដី
- កប់កូនគូលែនក្នុងរណ្តៅដោយធ្វើយ៉ាងណាអោយដីកន្ទោងកូនគូលែនស្មើមាត់រណ្តៅរួចយកមែកឈើដោតក្បែររណ្តៅចងទប់ជាមួយកូនគូលែន ។
- លប់ដីបន្តិចម្តងៗដោយសង្កត់ថ្នមៗហាម សង្កត់លើដីកន្ទោងកូនគូលែនដែលបណ្តាលអោយដាច់ឫស ។



## ៣.ការថែទាំនិងដាក់ជី:

- ខែវស្សារត្រូវពូនគល់ការពារទឹកជាំនៅគល់បណ្តាលអោយរលួយឫស ។
- នៅដើមរដូវប្រាំងគួរដាក់ជីបំប៉នដោយប្រើជីអាចម៍មាន់ឬអាចម៍ជ្រូកឬអាចម៍គោលាយជាមួយអង្កាមពុក,ចំបើងឬកំប្លោករលួយកាយកប់ក្នុងដីធ្វើជាកំពែង ។
- ប្រសិនបើកូនគូលែនមានសត្វល្អិតស៊ីត្រួយត្រូវប្រើថ្នាំសំលាប់សត្វល្អិត(ណាតូ) ។



## ៤.ការស្រោចទឹកៈ

- កូនគូលែនអាយុតិចជាង២ឆ្នាំត្រូវស្រោចទឹក១ដង ក្នុង១អាទិត្យនៅរដូវប្រាំង ។
- យើងត្រូវស្រោចទឹកតែម្តងគត់នៅពេលវាកំពុងផ្កា ។

## ៥.ការកាត់តែងមែកៈ

- ត្រូវកាត់ត្រួយចុងចេញនៅឆ្នាំទីមួយ ។
- ត្រូវកាត់មែកមិនសូវល្អចេញរៀងរាល់ឆ្នាំដោយទុកតាមប្រព័ន្ធ១-៣-៦-១៨(ដើម១-មែកធំ៣-ខ្នែងធំ៦ និងខ្នែងត្រួយ១៨) បើអាចធ្វើបានជាការល្អ។



*កាត់តែងមែកតាមប្រព័ន្ធ១-៣-៦-១៨*

- នៅពេលផ្លែគូលែនមានទំហំប៉ុនមេដៃយើងត្រូវបាញ់ថ្នាំសំលាប់សត្វល្អិត(ណាតូ)ទៅលើផ្លែដើម្បីការពារដង្កូវស៊ីផ្លែនៅពេលវាទុំ ។

## ៦.ការប្រមូលផលៈ

- មិនត្រូវបេះផ្លែគូលែនទំលាក់លើដីទេ ។
- ត្រូវបេះផ្លែគូលែនអោយមានជាប់ទងជាការប្រសើ

**អាចរកទិញកូនគូលែនបានតាមរយៈ**

១-អ្នកស្រី**ជា ធារិទ្ធ**,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរស្ពានទឹកវិល,ខ័ណ្ឌ-ក្រុងសៀមរាប,ទូរស័ព្ទលេខ:012 35 10 30/017 68 84 49

២-លោកគីម សុធា, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនបុប្ផាអង្គរ, ក្រុងសៀមរាប, ទូរស័ព្ទលេខ: 012 98 06

៣-លោកគីម ឈុំ,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, សួនច្បារអេដែន, ក្រុងសៀមរាប, ទូរស័ព្ទលេខ: 012 31 20 55

៤-លោកវ៉ាន់ ហឿន,អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ក្បែរផ្សារអង្រ្គង,ស្រុកប្រាសាទបាគងខេត្តសៀមរាប, ទូរស័ព្ទលេខ: 012 70 80 43

៥-អ្នកស្រីគីម សាវេត, អ្នកលក់ពូជឈើហូបផ្លែគ្រប់មុខ, ភូមិស្ពានជ្រាវ, ខ័ណ្ឌ-ក្រុងសៀមរាប, ទូរស័ព្ទលេខ: 089 80 54 66

សំរបសំរួលដោយ
កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ខេត្តសៀមរាប
FacilitatedbyRED-GreenBeltSiemReap

# ភាពជោគជ័យក្នុងការដាំគូលែន



## ការណែនាំអនុវត្តន៍ជាក់ស្តែងដោយៈ

លោកមួរ បេងលីម.លក់ពូជនិងដាំគូលែន
អាស័យដ្ឋានៈក្បែរវត្តនិរេវសន៍,ស្រុកមង្គលបូរី,
ខេត្តបន្ទាយមានជ័យ.ទូរស័ព្ទៈ ០១២ ៣៤៦ ៦០៦